# ការសំភាសន៍របស់មីងឈ្មោះនាង ស៊ីផាន

កៈអ្នកដែលសំភាសន៍ ហួន ឡាយហុក ខៈអ្នកដែលត្រូវបានគេសំភាសន៍ ស៊ី ផាន

កៈបាទ!អញ្ចឹងជំរាបសួរអ្នកមីងដែលអោយខ្ញុំសំភាសន៍ថ្ងៃនេះហើយការសំភាសន៍នេះគឺរៀបចំដោយសាកលវិទ្យាល័យBYUនៅសហរដ្ឋអាមេរិចដោយសកលនេះមានគោលបំណងចង់រក្សាពងប្រវិត្តិរឺគ្រួសាររបស់អ្នកមីងទុកដើម្បីកូនចៅជំនាន់ក្រោយរឺកូនអ្នកមីងស្គាល់ឪពុកម្ដាយរបស់អ្នកមីងឈ្មោះអីគេហើយអ្នករស់នៅកាលពីក្មេងអ្នករស់នៅយ៉ាងម្ដេចណាស់មីងណាស់។

ខៈចាំ!។

កៈអញ្ចឹងថ្ងៃនេះខ្ញុំអាចសុំការសំភាសន៍អ្នកមីងបានទេ។

ខៈចាំ!។

កៈបានណោះអ្នកមីងណោះ។

ខៈចាំ!។

កៈបាទ! អញ្ចឹងខ្ញុំចង់ដឹងថាឈ្មោះពេញរបស់អ្នកមីងឈ្មោះអីគេ។

ខៈឈ្មោះនាង ស៊ីផាន។

កៈនាង ស៊ីផាន។

ខៈចាំ!។

កៈចុះអ្នកមីងឥឡូវនេះសព្វថ្ងៃនេះអ្នកមីងអាយុប៉ុន្មានហើយ។

ខៈខ្ញុំអាយុ៦៣ឆ្នាំ។

កៈ៦៣ឆ្នាំហើយ។

ខៈចាំ!។

កៈអ្នកមីងមានគ្រួសារនៅ។

ខៈអត់។

កៈអត់ទាន់មានទេ។

ខៈមីងរស់នៅជាមួយជីដូនជីតាម្ដាយស្លាប់ចោល៦ខែនៅឪពុក។ ឪពុកបានអាយុ៩ឆ្នាំម៉ែក្មេងដណ្ដឹងប្រពន្ធទៀត។

កៈអញ្ចឹងចុះអ្នកមីងមនៅទីនេះគេហៅភូមិអីគេស្រុកអីគេ។

ខៈភូមិចុងកោះ ស្រុកស្រែកកណ្ដាល ខេត្តកណ្ដាល។

កៈអ៎! អញ្ចឹង។

ខៈចា៎។

កៈអញ្ចឹងអ្នកមីងរស់នៅទីនេះយូរហើយនៅ។

ខៈខ្ញុំយូរហើយតាំងពីខ្ញុំកើតមកឆ្នាំ១៩៥៦តែឥឡូវខ្ញុំបាន៦៣ឆ្នាំហើយតែខ្ញុំមានបងប្អូនបីនាក់ម្ដាយខ្ញុំស្លាប់ទៅ៧ឆ្នាំបងស្រីមួយនោះ៧ឆ្នាំស្លាប់ចោលទៅដល់សម័យនេះបងខ្ញុំប្រុសស្លាប់ចោលទៀតមានអាយុ៤៧ឆ្នាំស្លាប់ចោលស្លាប់ឆ្នាំ២០០០។ឥឡូវខ្ញុំរស់នៅតែម្នាក់ឯងទេជាមួយម្ដាយមីងអត់មានគ្រួសារដែលនៅជាមួយប្អូនជីទូតមួយសព្វថ្ងៃ។

កៈបាទ! អញ្ចឹងខ្ញុំចង់ដឹងថ្ងៃខែឆ្នាំកំណើតមីងថ្ងៃណាខែណាឆ្នាំណា។

ខៈខ្ញុំដឹងថាឆ្នាំ១៩៥៦តែកើតខ្ញុំមិនដឹងចាំថាថ្ងៃមិនដឹងរឿងថ្ងៃម៉ង។

កៈអ៎!។

ខៈអត់ដឹងថ្ងៃ។

កៈអត់ដឹងខែទៀត។

ខៈខែ៩។

កៈចុះសិនជាគិតចន្ទ័គតិឆ្នាំខ្មែរយើងដូចឆ្នាំជូត ឆ្លូវ។

ខៈឆ្នាំជូត ឆ្លូវ។ ខ្ញុំឆ្នាំវក។

កៈមីងឆ្នាំវក។

ខ៖ចាំ!ឆ្នាំវក។

ក៖បាទ! លើកមុខទីកន្លែងកំនើតអ្នកមីងលើកមុខនៅណា។

ខ៖នៅភូមិចុងកោះហ្នឹងម៉ង។

ក៖អំ! នៅហ្នឹងម៉ង។

ខ៖ចាំ!។

ក៖ចុះឪពុកម្ដាយ។

ខ៖ឪពុកម្ដាយពុកខ្ញុំស្រុកកំណើតនៅព្រែកថោងម៉ែខ្ញុំនៅកោះឧញ្ញាតីតែដល់ពេលខ្ញុំកើតមក ម៉ែខ្ញុំស្លាប់ទៅគាត់មកយកខ្ញុំនៅហ្នឹងម៉ង។

ក៖អំ!។

ខ៖មកនៅកោះហ្នឹងម៉ង។

ក៖អញ្ចឹងម្ដាយរបស់អ្នកមីងឈ្មោះអីគេ។

ខ៖ឈ្មោះហ៊ុន សម្បត្តិ។

ក៖ហ៊ុន សម្បត្តិ។

ខ៖ចាំ!ប៉ុន្តែជាហៅថាប៉ាត់។

ក៖គេហៅប៉ាត។

ខ៖ចាំ!។

ក៖អញ្ចឹងសព្វថ្ងៃហ្នឹងគាត់ស្លាប់ហើយ។

ខ៖ស្លាប់តាំងពីឥឡូវខ្ញុំ៦៦ខែហើយ។

ក៖អំ!។

ខ៖ឪពុកខ្ញុំស្លាប់តាំងតែពីខ្ញុំអាយុ២២ព្រោះបែកភ្នំពេញគាត់ស្លាប់១៩៧៧គាត់ស្លាប់។ចាទ! នៅយើងជុំលាស់ទៅបាត់ដំបង ពោធសាត់។ គាត់ស្លាប់នៅហ្នឹង។

កៈចុះពេលដែលម្ដាយរបស់អ្នកមីងស្លាប់ក្នុងឆ្នាំណា។

ខៈដឹងថាឆ្នាំខ្ញុំកើតហ្នឹងម៉ងឆ្នាំវកហ្នឹងម៉ង។

កៈអញ្ចឹងរយៈពេលប៉ុន្មានឆ្នាំបានម្ដាយមីងស្លាប់មីងអាយុប៉ុន្មានឆ្នាំ។

ខៈ៦ខែ។

កៈអ៎!៦ខែបានគាត់ស្លាប់។

ខៈចា៎! អញ្ចឹងបានថាស្លាប់ក្នុងឆ្នាំខ្ញុំកើតហ្នឹងម៉ង។

កៈអញ្ចឹងអ្នកមីងមានដឹងថាឪពុកម្ដាយរបស់ម្ដាយអ្នកមីងឈ្មោះអីគេ។

ខៈឈ្មោះហ៊ុន សម្បត្តិហៅប៉ាត់។

កៈហ្នឹងខាង។

ខៈហ្នឹងខាងម្ដាយឪពុកខ្ញុំឈ្មោះនាង មឿន។

កៈអ៎! នាង មឿន។

ខៈចា៎!។

កៈខាងម្ដាយដូចគ្នា។

ខៈមួយខាងឪពុកមួយខាងម៉ែ។

កៈអញ្ចេកខ្ញុំចង់ដឹងថាខាងម៉ែ។

ខៈបើម្ដាយគាត់ហ៊ុន សម្បត្តិហ្នឹងឈ្មោះសុខ បូ។ ហ៊ុន នៅជាឈ្មោះរបស់ឪពុក។

ចា៎!។

កៈចុះឪពុករបស់មីងឈ្មោះអីគេ។

ខៈឈ្មោះនាង មឿន។

កៈនាង មឿនចុះតារបស់ខាងឪពុករបស់មីងហ្នឹង។

ខ៖ឈ្មោះគេហៅតែតានាង។

ក៖តានាង។ចុះម្ដាយ។

ខ៖ម្ដាយយីអុន។

ក៖ម្ដាយយីអុន។

ខ៖ចាំ!។

ក៖អត់ស្គាល់ត្រកូលគាត់ទេ។

ខ៖អត់ស្គាល់ត្រកូលព្រោះយើងនៅតូចណាស់យើងមិនស្គាល់គេហៅតែតានាង យីអុន។

ក៖បាទ!។

ខ៖ចាំ!។

ក៖នៅពេលហ្នឹងមីងមានចាំថាយីតាខាងម្ដាយរបស់អ្នកមីងគាត់ប្រកបមុខរបបរអីគេកាលពីមុខ។

ខ៖ចំការ។ ធ្វើចំការរហូត ធ្វើចំការមកមិនមានអីទេមុខរបបរចំការរហូតដូចយើងដាំថ្នាំជក់ខ្ទឹមបារាំង ខ្ទឹអី ត្រាវទាំងអស់ត្រសក់អីចាស់ៗពីដើមមកធ្វើពីដើមមក។ចាំ!។

ក៖ហើយចុះម្ដាយរបស់មីងហើយនិងឪពុករបស់មីងគាត់ប្រកបរមុខរបបរអីគេ។

ខ៖ប្រកបមុខរបបរហាន់ថ្នាំធ្វើចំការហាន់ថ្នាំជក់ហ្នឹង។

ក៖អញ្ចឹងមានន័យថាគាតប្រកបមុខរបបរដូចតាគាត់ដែល។

ខ៖ចាំ!ដូចដែល។

ក៖អ៎!ហើយចុះខាងឪពុករបស់មីងវិញ។

ខ៖ខាងឪពុកខ្ញុំនាង មឿនហ្នឹងអី។

ក៖ហ្នឹងហើយ។

ខ៖ក៏អញ្ចឹងដែលធ្វើចំការដូចតែគ្នា។

ក៖ធ្វើចំការដូចគ្នាពួកគាត់នៅខេត្តណាដែល។

ខ៖នៅខេត្តកណ្ដាលដូចគ្នា។

ក៖អ៎! ដូចគ្នា។

ខ៖គ្រាន់តែភូមិព្រែកដង្កោ មួយទៀតភូមិព្រៃលួងតែប៉ុណ្ណឹងទេ។

ក៖អ៎! ខុសភូមិឃុំ។

ខ៖ខុសភូមិឃុំ។ ចា៎!។

ក៖ខេត្តដូចគ្នា។

ខ៖ចា៎!ខេត្តដូចគ្នា។ ស្រុកស្រែកណ្ដាលដូចគ្នា។

ក៖អញ្ចឹងចង់ដឹងថាឪពុករបស់មីងកើតនៅឆ្នាំណាដែល។

ខ៖គាត់ឆ្នាំរោងបើនៅដល់ឥឡូវ៩០ជាង។

ក៖អ៎!៩០ជាង។

ខ៖ចា៎!។

ក៖កាលហ្នឹងគាត់កើតអីគេបានស្លាប់។

ខ៖ចា៎!
អាពតប្អអត់បាយកាលជំនាន់អាពតបងឪពុកខ្ញុំ៥នាក់ស្លាប់នៅហ្នឹងទាំងអស់ម្ដាយធំម្ដាយមីង
អីស្លាប់នៅហ្នឹងទាំងអស់។

ក៖ចុះមីងមានចាំឈ្មោះពួកគាត់ទេ។

ខ៖ចាំតើនាង គ្រឿងបងបង្អស់នាង មឿន។នាង មឿន ឪពុកខ្ញុំ។
ប្រហែល៥នាក់ស្លាប់ទាំងអ៊ែស្លាប់នៅពោធសាត់ទាំងអស់។

ក៖នៅពោធសាត់។

ខ៖ចា៎!។

ក៖ចុះខាងម្ដាយមីងមានចាំបងប្អូនគាត់។

ខ៖ម្ដាយនៅមីងខ្ញុំស្លាប់តែម៉ែខ្ញុំហ៊ុន សម្បត្តិហ្នឹងមកហ៊ុន
ជ្រូកទើបតែស្លាប់បាន៣ឆ្នាំហើយណាស់ហ៊ុន មឿនស្លាប់បាន៥ហើយមកហ៊ុន សុខហើយហ៊ុន
ណានស្លាប់ជំនាន់ពុលពតហ៊ុន មឿនស្លាប់ជំនាន់ពុលពតហ៊ុន
ជនស្លាប់ពីសង្គមឡើងដើមដូងធ្លាក់ដើមដូង។

ក៖អ៎!។

ខ៖ចាំ! អាយុទើបតែ១៣ឆ្នាំទេស្លាប់ហ្នឹងពៅគេបង្អស់មីងហ៊ុន
នឿនខ្ញុំហ្នឹងហៅយួនហ្នឹងគាត់នៅក្រចេះហ្អ៎នៅឈ្លូងមានប្តីទៅនៅហ្នឹងស្លាប់ជំនាន់អាពតដែ
ល។

ក៖អញ្ចឹង។

ខ៖ចាំ!ហ៊ុន ណានហ្នឹងហៅពូហួតហ្នឹងស្លាប់ជំនាន់ពុលពត។

ក៖អ៎!។

ខ៖ចាំ!។

ក៖ពេលហ្នឹងកើតអីបានគាត់ស្លាប់។

ខ៖សុទ្ធតែជំងឺអត់បាយទាំងអស់។

ក៖អត់បាយ។

ខ៖ចាំ! ជំងឺអត់បាយទាំងអស់បានសេចក្តីវេទនាវាអញ្ចឹង។

ក៖អញ្ចឹងចុះពេលដែលមីងអើយម្ដាយឪពុករបស់មីងមានកូនចំនួនប៉ុន្មាននាក់។

ខ៖ឪពុកម្ដាយខ្ញុំមានកូនតែបីនាក់ហ្នឹង។

ក៖ណាគេខ្លះ។

ខ៖បីនាក់ហ្នឹងបងនាង សាវឿនហ្នឹងស្លាប់បាត់ហើយអាយុ៧ឆ្នាំ។

ក៖បាទ!។

ខ៖បាននាង សុផាតហ្នឹងស្លាប់ឆ្នាំ២០០០បានអាយុ៥៧ឆ្នាំ។

ក៖អ៎!។

ខ៖ខ្ញុំញ៉ាំគេ។

ក៖ចុះបងរបស់មីងគាត់មានប្តី។

ខ៖មានប្រពន្ធប្រុសតើ។

ក៖មានប្រពន្ធណោះ។

ខ៖មានប្រពន្ធនៅសព្វថ្ងៃ។

ក៖ប្រពន្ធរបស់គាត់ឈ្មោះអីគេ។

ខ៖ឈ្មោះសុខ សំអាង។

ក៖ហើយចុះរាល់ថ្ងៃគាត់នៅណា។

ខ៖នៅធ្វើការនៅហាងទឹកសុទ្ធណោះនៅឃ្លាំងទឹកសុទ្ធធ្វើ។

ក៖គាត់ស្លាប់ប៉ុន្មានឆ្នាំហើយ។

ខ៖ឆ្នាំ២០០០មកឥឡូវឆ្នាំ២០១៨ហើយ។

ក៖អ៎! អញ្ចឹង។

ខ៖គិតទៅ១៨ឆ្នាំហើយតើ។

ក៖ចុះអើយ។

ខ៖កូននៅតូចៗ។

ក៖គាត់មានកូនដែលណោះ។

ខ៖កូនសព្វថ្ងៃនៅតូចៗ។

ក៖មានចាំកូនគាត់ឈ្មោះអីគេអត់។

ខ៖ឈ្មោះផាត សុជាតិ។ផាត ពិសិត។ ផាន វិសាល។ ផាន ស្រីលក្ខណ៍។ ផាត ស្រីលៀប។

ក៖អញ្ចឹង។

ខ៖ចាំ!។

ក៖ប្រុសប៉ុន្មានស្រីប៉ុន្មាន។

ខ៖ប្រុសបីស្រីពីរតែប្រពន្ធមុខស្រីមួយប្រុសបី។
ប្អូននាក់ហ្នឹងតែមួយទៀតដែលមានប្រពន្ធមួយទៀតហ្នឹងតែវារាប់អានគ្នាដូចបងប្អូនបង្កើតគ្នារាប់អានទៅវិញទៅមកស្រឡាញ់ដូចបងប្អូនបង្កើតទេ។

ក៖បាទ!

ខ៖បានស្រីពីរប្រុសបី។

ក៖អ៎!។

ខ៖សព្វថ្ងៃ។

ក៖អញ្ចឹងមានន័យថាគាត់បានប្រពន្ធពីរដង។

ខ៖មានប្រពន្ធពីរដង។

ក៖ហើយឥឡូវគាត់ធ្វើការនៅកន្លែងទឹកសុទ្ធ។

ខ៖ធ្វើនៅកន្លែងទឹកសុទ្ធមិនបានប៉ុន្មានទេខំជិះកង់ទៅធ្វើការ។ ចាំ!
គ្រាន់តែវាបានបង់ប្រាក់រដ្ឋបង់អីទៅណាស់យកប្រាក់រដ្ឋយើងខំរកស៊ីសព្វថ្ងៃវាមិនបានសល់ទេអត់អីសល់ទេ។

ក៖ហើយចុះបងទីពីរ។បងទីពីរឈ្មោះអីគេ។

ខ៖បងខ្ញុំនិងអី។

ក៖ហ្នឹងហើយ។

ខ៖នាង សុផាតហ្នឹងដែលស្លាប់ហ្នឹងកូនរបស់នាងសុខ ផាតហ្នឹងហើយ។ផាត
សុជាតិហ្នឹងកូន៥សព្វថ្ងៃមានកូន៥។

ក៖បាទ!ឈ្មោះអីគេខ្លះ។

ខ៖កូនវាហ្នឹងអី។

ក៖បាទ!

ខ៖សុជាតិ នីតាថ្នាក់ទី៦ហើយ សុជាតិ សំភ័សថ្នាក់ទី៥។សុជាតិ ខែមម៉ាថ្នាក់ទី៣ហើយ។ សុជាតិ ខែមរាទើបតែចូល។ សុជាតិ រចនាទើបតែ២ខួប(២ឆ្នាំ)ជាង។

ក៖អញ្ចឹងកូនគាត់ប៉ុន្មាននាក់ហ្នឹងរៀននៅណាវិញ។

ខ៖រៀននៅសាលាបថមសិក្សាចុងកោះហ្នឹង។

ក៖នៅឆ្ងាយពីនេះប៉ុន្មាន។

ខ៖ឆ្ងាយប៉ុន្មានទេនៅជិតខ្លោងធ្វេវត្តតីប៉ាវ្សាន្តមកពីស្ពានហ្នឹងមកវត្តទីប៉ាវ្សាន្តខ្លោងធ្វេហ្នឹង រៀនបួនសព្វថ្ងៃរៀនបួននៅមួយប៉ុន្តែគ្នាប្រាក់ខែមិនគ្រប់គ្រាន់ទេព្រោះអង្កផងទឹកផងម្ហូបផងវា មិនគ្រប់គ្រាន់ទេរកតែលុយស្ទូចផ្ទះមកបានផង។ បាត់បែកលិចលុងអស់ហើយផ្ទះ។

ក៖អញ្ចឹងសព្វថ្ងៃនេះមីងប្រកបមុខរបបរអីគេ។

ខ៖ខ្ញុំនៅស៊ីឈ្នួលគេហ្នឹង។

ក៖ស៊ីឈ្នួលគេ។

ខ៖ចាំ! នៅជាមួយប្អូនជីទូតមួយអោយមើលម៉ែគេផងបោះផ្ទះគេសំអាតផ្ទះគេ។

ក៖អំ! មីងធ្វើនៅហ្នឹងប៉ុន្មានឆ្នាំហើយ។

ខ៖ទើបធ្វើមិនទាន់បានមួយឆ្នាំផងនៅជាមួយគេហៅមកនៅជាមួយ

ក៖ចុះពីមុខ។

ខ៖ពីមុខខ្ញុំនៅផ្ទះខ្ញុំរកស៊ីធម្មតា។ខ្ញុំមុខរបបខ្ញុំធ្វើចំការដែលកាលពីជំនាន់គ្រាប់ឈូកខ្ញុំរកគ្រាប់ ឈូកដល់ខ្ញុំចុះចំការរកទិញអីវ៉ាន់អីទៅដោះដូរអង្កគេមកហូបមក។

ក៖ចុះពេលដែលមីងបែកពីឪពុកម្តាយកាលហ្នឹងមីងប្រកបមុខរបបរអីគេកាលហ្នឹង។

ខះខ្ញុំបែលពីឪពុកម្តាយតាំងពីតូចមកខ្ញុំនៅជាមួយជីដូនជីតាខ្ញុំ។

កះអ៎!នៅជាមួយជីដូនជីតា។ កាលហ្នឹងបានរៀនអត់មីង។

ខះខ្ញុំរៀនបានថ្នាក់ទី៧ពីសង្គម។

កះថ្នាក់ទី៧ពីសង្គម។

ខះចា៎!។

កះមីងចេះអានអក្សរខ្មែរទេ។

ខះខ្ញុំអានតួរអក្សរបារាំងចាំទាំងអស់គ្រាន់តែវាភ្លេច។

កះអ៎! ចាំអក្សរបារាំង។

ខះចា៎!។

កះអញ្ចឹងកាលមុខមីងរៀនខ្មែរផងបារាំងផង។

ខះបារាំងរៀនបានបន្តិច។

កះអ៎!។

ខះបារាំងរៀនថ្នាក់ទី៩បានបន្តិចដល់ពេលគេប្រជុំទំលាក់សម្តេចគ្រូប្រជុំៗគ្មានបានរៀនទេ។

កះអ៎!។

ខះគ្មានបានរៀនទេ។

កះនៅពេលដែលមីងប្រកបមុខរបបរពីមុខមក

ខះចា៎!។

កះជីវភាពរបស់មីងម៉េចដែលរកស្រួលទេ។

ខះជីវភាពធម្មតាមិនក្រមិនមានគ្រាន់ថាគ្មានផ្ទះខ្សឹង
គ្មានសម្បត្តិទូរទុកៅអីដាក់ផ្ទះទេគ្រាន់ថាជីដូនជីតាខំរកស៊ីចិញ្ចឹមថៅអោយរៀនបងខ្ញុំអោយរៀនបានថ្នាក់បាក់ឌុប(ថ្នាក់ទី១២)ប្រលងនៅសល់ខែពីរខែបែកភ្នំពេញប្រលងបាក់ឌុបខែ៧។

ទីបញ្ចប់បងខ្ញុំស្លាប់ទៅបានសញ្ញាបត្រឌីភ្លូមអីសង្គមគាត់ខំតស៊ូអោយចៅរៀនរកអោយចៅរៀនគ្រូហៅខំទៅប្រលងដែលតែខ្ញុំអត់ទៅព្រោះមើលទៅគាត់ពិបាកពេករកស៊ីចិញ្ចឹមយើង។

កៈចុះមីងមានចាំថាសាលាពីមុខឈ្មោះអីគេកាលមីងរៀន។

ខៈឈ្មោះភូមិចុងកោះហ្នឹង។

កៈចុះពេលហ្នឹងមីងឈប់រៀបអាយុប៉ុន្មានឆ្នាំ។

ខៈខ្ញុំឈប់រៀនដូចជាអាយុ១៣ឆ្នាំ។

កៈ១៣ឆ្នាំមីងឈប់រៀនណោះ។

ខៈចាំ! ខ្ញុំឈប់រៀន។

កៈកាលហ្នឹងកើតអីបានឈប់រៀន។

ខៈខ្ញុំជីវភាពក្នុងគ្រួសារវារត់មិនរួចថាសមត្ថភាពយើងបើរៀនទៅបានតែជីវភាពគាត់ខំរកស៊ីចិញ្ចឹមយើងពិបាកណាស់នៅជាមួយតាយីគាត់ចាស់ហើយ។

កៈបាទ!ពេលហ្នឹងតាយីគាត់រកអីគេ។

ខៈគាត់ធ្វើចំការ។

កៈធ្វើចំការ។

ខៈចាំ!។

កៈធ្វើចំការគាត់ដាំអីគេ។

ខៈគាត់ដាំថ្នាំជក់ ដាំត្រសក ដាំគ្រប់មុខនិយាយទៅប៉េងប៉ោះដាំទាំងអស់ហ្នឹង។

កៈពេលហ្នឹងគាត់យកទៅលក់នៅទៅផ្សារខ្លួនឯងរឺមានឈ្មួញគេមកយក។

ខៈជូនកាលគេមកទិញដល់ចំការជូនកាលខ្ញុំប៉ះយកទៅលក់ទៅផ្សារចាស់ពីដើមផ្សារកំពង់ទឹកកកពីដើមហ្នឹងហើយទៅប៉េងបោះ ស្វាយទៅទាំងអស់ទៅលក់នៅហ្នឹងទាំងអស់។

កៈពេលហ្នឹងដីគាត់ចំនួលប៉ុន្មានហេតាដែល។

ខះពេលហ្នឹងដីហ្នឹងយើងជួលគេ។

កះអំ! ជួលគេ។

ខះជួលគេធ្វើប៉ុន្តែជិតបែកភ្នំពេញគេចង់លក់អោយដល់ពេលបែកភ្នំពេញអញ្ចឹងទៅវាអត់បាន
។

កះអំ!។

ខះជួលគេរាប់ឆ្នាំតាំងពីខ្ញុំតូចរហូត១០ឆ្នាំ។

កះអញ្ចឹងមីងចេះធ្វើចំការអីដែល។

ខះចេះ។

កះពេលហ្នឹងអ្នកណាជាអ្នកបង្រៀនរឺមីអ្នកចេះខ្លួនឯង។

ខះចេះខ្ញុំទៅដាំដំណាំទៅជាមួយជីដូនជីតាហ្នឹងទៅធ្វើទៅ។

កះចុះមីងចេះអីក្រៅពីហ្នឹងទៀតអត់ដូចជាដេរជំបាញដេរខោអាវ។

ខះដេរមិនចេះទេព្រោះអត់បានរៀនបានសូត្រទេព្រោះធ្វើចំការហ្នឹងទៅពេលខ្ញុំពេញវ៏យជំនាន់
លុនណុលហ្នឹងជំនាន់ទាហានហ្នឹងវាចង់តែចាប់យើងដល់ផ្ទះអីនោះកាលហ្នឹងឃើញមិនបាន
ទេពួកទាហានតាមចាប់ដល់ផ្ទះ។

កះវាចាប់ធ្វើអីគេ

ខះវាតាមចាប់ចាប់យើងធ្វើប្រពន្ធវាហ្នឹងយើងពេញវ៏យនិយាយទៅយើងពេញក្រមុំ។
តាខ្ញុំមិនអោយចុះចំការទេអោយនៅផ្ទះមិនអោយដើរទេកាលជំនាន់ហ្នឹង។

កះអញ្ចឹងកាលពីសម័យពុលពតកាលហ្នឹង។

ខះខ្ញុំអាយុ២០ឆ្នាំហើយ។

កះ២០ឆ្នាំហើយ។

ខះ២០គត់ទៅវិហាសួរតែខ្ញុំទៅវិហាសួរខ្ញុំអរគុណព្រះអង្គវិហាសួរលោកជួយដែលមិនពិបាកវេ
ទនាអីទេពិបាកអីដូចមូលដ្ឋានចាស់មូលដ្ឋានថ្មីស្រលាញ់ទាំងអស់ដូចថាដូចមាននិស្ស័យនៅ

ខាងហ្នឹងដូចពួកពេទ្យអីគេអានឹតសព្វគ្រប់ខ្ញុំមានអញ្ចេកមានគោលបំណងមួយជំនាន់ពុលពត ហ្នឹងមានគូរដណ្តឹងមួយជំនាន់ហ្នឹងថាឈ្មោះពូលីមទោះគេមកដណ្តឹងក៏មិនបានដែលព្រោះ យើងមានខ្នង(មានគេចាំជួយ)ហើយវាមិនហ៊ានធ្វើអីយើងទេដល់ពេលដណ្តឹងមិនបានវាលើក អង្គប្រជុំថាយើងខុសសីលធម៌ហើយរកយកទៅវៃហើយមានបានវៃណាវាវៃចោលយើងមិនកើ តដូចព្រះអង្គលោកយូព្រះវិហាសួលោកយូរម៉ងដូចគ្មានអោយពិបាកសូម្បីពួកវៀតណាមដាក់ ផ្ទះខ្ញុំទាំងអស់ដូចមាននិស្ស័យម៉ងមូលដ្ឋានចាស់មូលដ្ឋានថ្មីស្រលាញ់ទាំងអស់គេចង់បានខ្ញុំ ច្រើនតែខ្ញុំមិនយក។

ក៖អញ្ចឹង។

ខ៖ចាំ!។

ក៖ចុះពេលហ្នឹងពេលទាហានគេមកចាប់អ្នកមីងគេចាប់យកធ្វើប្រពន្ធ។

ខ៖ចាំ!។

ក៖ហើយចុះខ្ញុំចង់ដឹងថាពីសម័យដែលពុលពតហ្នឹងមីងឆ្លងកាត់ហើយតើមីងឆ្លងកាត់ការលំបា កអីគេខ្លះនៅសម័យនោះ។

ខ៖សម័យនោះឆ្លងកាត់ការលំបាកគ្រាប់លំសៀវ។ ចាំ!
យើងវៃគ្នាកាលជំនាន់ឆ្នាំ១៩៧៩ផ្លោងពីស្វាយជ្រុំដល់អារីខ្សាត់អីមករត់ទៅនៅយៀនឃ្លាំងជិះ ទូកទៅដេកពួកនៅកៀនឃ្លាំងទាំងអស់ពូខ្ញុំស្លាប់ដោយសារទៅយកម៉ាស៊ីនធ្វើគ្រាវ អាប៊េបុកស្លាប់ពូថ្លៃបង្កើតឈ្មោះទៀង ឡោស្លាប់។

ក៖អញ្ចឹងកាលហ្នឹងមីងធ្វើអីគេខ្លះ។

ខ៖នៅចំការកាលហ្នឹងធ្វើចំការជំនាន់លុនណុលដល់វៃខ្លាំងពេកទៅមិនហ៊ានទៅចំការទេចោ លគ្រាវហ្នឹងដល់គេជំលាស់ទៅគ្រាវនៅចំការទាំងអស់។

ក៖ចុះជំនាន់ពុលពត។

ខ៖ជំនាន់ពុលពតទៅណោះចុះធ្វើពលកម្មជាមួយគេស្ទូងស្រូវដកសំណាបទៅទូជីទៅណា ក្រោកពីយប់ទៅឆ្ងាយណាស់។

កះកាលហ្នឹងគេអោយក្រោកម៉ោងប៉ុន្មានមីងមានដឹង។

ខះក្រោកទាំងពីម៉ោង៣។

កះចុះពេលដេក។

ខះពេលដេកយើងដេកទៅដល់ហើយវាដាស់ហៅក្រោកទៅ។

កះកាលហ្នឹងដេកម៉ោងប៉ុន្មាន។

ខះចាប់ដេកម៉ោង៨ជាងអីដេកហើយប៉ុន្មានវាជំនាន់ពុលពតសរសើរថាត្រង់ដេកពួកយើងកុំអោយដេករយេ៉រយៃ៉មានសណ្តាប់ធ្នាប់អញ្ចឹង។

កះបាទ!
អញ្ចឹងពេលដែលមីងជួបកាលសម័យពុលពតហ្នឹងណាស់មីងបានហូបចុងអីគ្រប់គ្រាន់ទេ។

ខះការហូបចុកវាមិនទាន់បានបាយទេគឺបបរទេណាស់តែចំណីយូរៗគេធ្វើមួយម្តង៣ថ្ងៃគេធ្វើមួយដងនៅវិហាសួវាដោយកន្លែង។ ចា៎!
របបរលាយជំឡូងឈ្វាតែរបស់ហ្នឹងខ្ញុំហូបមិនដែលអស់ទេ។ចា៎!
តែម្ហូបគេធ្វើខ្ញុំមិនសូវហូបទេព្រោះថាយើងបានគេអោយចិញ្ចឹមសត្វខ្លួនឯងអូខ្លះអញ្ចឹងទៅដាំដំណាំភូមិដែលគេអោយហ្នឹងធ្វើពោងនៅដាំពោត
ដំាបន្លែអីមាន់យើងកាប់ហូបទៅតែកណ្តុលខ្ញុំមិនដែលហូបដល់សព្វថ្ងៃខ្ញុំមិនដែលហូបទេរឿងសត្វកណ្តុលមិនដែលហូបសោះ។

កះអញ្ចឹងបានន័យថាមីងពេលជំនាន់ហ្នឹងមិនសូវលំបាកប៉ុន្មានទេ។

ខះអត់សូវលំបាកអីទេ
អត់សូវលំបាករឿងកំលាំងពលកម្មហ្នឹងយើងធ្វើយើងមិនមានមិនសេះទេណាស់។

កះបាទ!។

ខះយើងដាក់កំលាំងធម្មតា។

កះហ្នឹងហើយ។

ខះហ្នឹងហើយបើពិសេសគេទៅទប់ព្រៃក

លើកទំនប់យើងអត់មានទៅពិសេសទេព្រោះថានិយាយទៅមានព្រះជួយអញ្ចឹងម៉ងជួយរូបខ្ញុំមួយគឺមិនសូវពិបាកជាងគេម៉ងនិយាយរួចទៅអត់សូចពិបាកជាងគេទេព្រោះអញ្ចេកបានថាមិនសូវពិបាកដូចគេស្រឡាញ់យើងអ្នកមូលដ្ឋានចាស់មូលដ្ឋានថ្មីអីគេស្រលាញ់យើងទាំងអស់ស្ម្បីទាហានពួកអាពតក៏វាមិនហ៊ានធ្វីអីយើងដែលឃើញយើងដូចមាននិស្ស័យដូចថាបារមីលោកថៃយើងម៉ងនិយាយអញ្ចេកវិញ។

កះអត់មានអ្នកធ្វើបាបយើង។

ខះមិនសូវមានអ្នកធ្វើបាបមានតែវាអង្វយើងកុំអោយទៅបាត់ដំបងកុំចង់ទៅធ្វើមុខអោយសស់ទៅខ្ញុំមុខអត់រីកមែនដូចថាបែកបងបែកមាមីងបងខ្ញុំគេចាប់ទៅបែកគ្នាទៅដូចបែកបងបែកប្អូនបែកមីងអញ្ចឹងទៅគេជំលាស់ទៅបាត់ដំបងរាងខ្លួនទៅអញ្ចឹងដូចថាបែកបាក់អញ្ចឹងម៉ងដូចថាបែកបាក់គ្រួសារបងប្អូនអញ្ចឹង។

កះអញ្ចឹងចុះនៅពេលដែលបងប្អូនមីងនៅជំនាន់ហ្នឹងគាត់ធ្វើអីគេដែល។

ខះវាយកទៅធ្វើទាំងអស់។

កះជុំគ្នាទាំងអស់អត់បែកទេ។

ខះទៅបាត់ដំបង។

កះបាត់ដំបង។

ខះគេជំលាស់ទៅបាត់ដំបងបានស្លាប់ហ្នឹង។

កះអ៎!។

ខះពូខ្ញុំស្លាប់ពេលដែលគេជំលាស់ទៅបាត់ដំបងពុកខ្ញុំបែកនៅព្រៃកថោងនេះមិនទៅជាមួយខ្ញុំទេពុកខ្ញុំនៅជាមួយម៉ែខ្ញុំដណ្ដឹងប្រពន្ធ១៩ឆ្នាំការឈ្មោះមីងរីនឈ្មោះហួ

រីនម្ដាយចុងខ្ញុំប៉ុន្តែស្លូតណាស់ស្រលាញ់ខ្ញុំណាស់ខ្ញុំបានអាយុ៩ឆ្នាំគាត់ដណ្ដឹងម្ដាយមីងដណ្ដឹងអោយហើយការអោយទៀតម៉ែក្មេកពុកខ្វមដណ្ដឹងអោយទៀតយីខ្ញុំបង្កើតខ្ញុំនៅជាមួយគាត់ហើយឪពុកខ្ញុំនៅជាមួយគាត់ទាំងពី៦ខែដល់៩ឆ្នាំគិតមើលទៅចិត្តគាត់បានណាស់ស្រលាញ់កូនប្រសារកគ្មានទេហើយមកដល់សម័យនេះខ្ញុំចិញ្ចឹមកូនកំព្រាទៀត។

កៈអញ្ចឹង។

ខៈចិញ្ចឹមប្អូនកំព្រាទៀតពីរនាក់មួយបានការអោយមួយទៀតមិនបានការអោយ។

កៈអញ្ចឹង

ខៈចាំ! មួយសព្វថ្ងៃឈ្មោះសុខ សាន្ត។ខ្ញុំការអោយប្រពន្ធហើយមួយឈ្មោះវ៉ា ស៊ីថេងនៅកំពង់ធំសព្វថ្ងៃគេទៅយកប្រពន្ធខ្លួនគេតែគេនៅរាប់អានយើងគោរពស្រឡាញ់យើងដូចជាបង

កៈអញ្ចឹងអ្នកដែលមីងការអោយហ្នឹងប្រពន្ធគាត់ឈ្មោះអីគេ។

ខៈឈ្មោះពេជ្រ ណារីនទើបតែការកូនវាមួយថ្ងៃណោះខែមុខនេះ។

កៈគាត់ធ្វើមុខរបបរអីគេ។

ខៈគេរកស៊ីលក់ដូរនៅផ្សារពីមុខមកគេផ្សាញគេល្វែអីអញ្ចឹងណាស់។

កៈអំ!។

ខៈគេមានមុខរបបរគេខ្ញុំត្បាញក្រមាចេះតែតិចដែលទេសំពតមិនចេះទេ។

កៈចេះធ្វើក្រមា។

ខៈចាំ!។

កៈចុះមីងធ្វើរាល់ថ្ងៃទេ។

ខៈអត់បានធ្វើទេព្រោះយើងមិនមានដើមទុនអីធ្វើទេហើយមួយទៀតយើងចាស់ហើយដូចថាខាអំបោះអីមិនសូវរហ័សព្រោះអីមុខរបរនេះយើងមិនដែលធ្វើទាំងពីតូចយើងរកស៊ីតែលក់ដូរនិយាយរួមបើលកើដូរខ្ញុំទៅរួចតែឥឡូវវានឿយណាយក្នុងចិត្តខ្ញុំដូចថាកំលាំងចាស់ទៅលេងរួចណាក្អយផងមាននេះណាអត់វាអត់សព្វគ្រប់បែបយ៉ាងមានអី។

កៈហើយចុះមីងមានចាំមិត្តភក្រ័របស់មីងកាលនៅជំនាន់ដែលមីងរៀនមីងមានចាំឈ្មោះពួកគាត់អត់មិត្តភក្រជិតស្និតម៉ង។

ខ៖រឿនការជិតស្និតអត់មានជាការជិតស្និតតែគ្រាន់ថាជាការរស់នៅសព្វថ្ងៃឈ្មោះថាងហ្មឹងមួយក្រពុំនៅច្រើនដែលនៅម៉ែមីពុំមួយមួយទៀតយុត បុណ្យថឿន។បាត
ស៊ីផុតសព្វថ្ងៃធ្វើអាចារ្យ។ យីសុងស្លាប់ហើយរៀននៅច្រើនគ្នាណាស់។

ក៖តែឥឡូវគាត់នៅរស់ទាំងអស់គ្នា។

ខ៖នៅរស់តែស្លាប់ច្រើនដែល។

ក៖អ៎!។

ខ៖ស្លាប់ច្រើន។

ក៖អញ្ចឹងនៅចាំមិត្តភក្រច្រើន។

ខ៖ចាំច្រើនអត់អីទេចាំច្រើនរាល់ថ្ងៃមានមិត្តភក្រ័មួយសម័យហោងសំរឹននេះឈ្មោះម្ហូងសុខនទៅនៅអាមេរិចកាលមុខគេជួយខ្ញុំដល់ឥឡូវប្តីគេធ្វើបាបពេកប៉ុន្មានឆ្នាំនេះមិនបានជួយមកទេកាលនោះលុយគេអោយខ្ញុំ១០០$ធ្វើក្រម៉ាទិញធ្វើដើមទុកធ្វើក្រម៉ាធ្វើអីណាស់គេអោយមកគេចិត្តបានណាស់។ខ្ញុំចូលសិល្ប១០ឆ្នាំជាងហើយតាំងពីឆ្នាំ២០១៥ម្លោះរក្សាសិល្ប៥។ចា៎!
។

ក៖អញ្ចឹងពេលដែលអ្នកមីងមកនៅទីនេះអ្នកមកកីងមកជួយធ្វើការផ្ទះអោយគេណោះ។

ខ៖ចា៎! នៅបោះសំណាតថៃទាំផ្ទះគេទៅ។

ក៖ចុះនៅពេលដែលមីងកាលមីងនៅរៀនកាលជំនាន់មុខមីងធ្លាប់មានក្តីស្រមៃថាចង់ធ្វើអីពេលធំឡើងអត់។

ខ៖ខ្ញុំចិត្តខ្ញុំប្រាប់ត្រង់ចង់ធ្វើគ្រូបង្រៀនសម័យអោយបានប្រឡងធ្វើបង្រៀនតែខ្មោចតាខ្ញុំមិនអោយទៅ។

ក៖ម៉េចអញ្ចឹង។

ខ៖គាត់ខ្លាចទៅនៅស្រុកគេបែកពីគាត់។

ក៖អ៎! ទៅអញ្ចឹង។

ខ៖ចាំ! គេដាក់ឌីម៉ង់ហើយអស់ហើយសម័យហ្នឹងតែមិនបានទៅប្រលងគាត់មិនអោយទៅ។

ក៖ម៉េចអញ្ចឹងម៉េចមិនអោយទៅ។

ខ៖ដូចថាគាត់មិនអោយចៅណាគាត់ទើបស្លាប់១៩៧៥ហ្នឹងតើគាត់ស្លាប់។ចាំ!។

ក៖គាត់ថាម៉េចបានមិនអោយប្រលង។

ខ៖គាត់ខ្លាចទៅនៅស្រែអីពិបាកវេទនាអីគាត់មិនអោយទៅទេមិនបានទៅនិយាយរួចនិស្ស័យយើងមិនបានធ្វើម៉ងនិយាយចំ។

ក៖ចុះមីងគិតថាម៉េចបានជាចង់ក្លាយជាគ្រូបង្រៀន។

ខ៖ខ្ញុំចង់ធ្វើគ្រូបង្រៀងថាយើងមានកំរិតទៅបានពន្យល់កូនចៅអីអញ្ចឹងណាស់បានចេះអក្សរអីទៅយើងជាមាតាបីតាទី២របស់គេ។

ក៖បាទ!ហ្នឹងហើយ។

ខ៖ហ្នឹងហើយបើយើងមិនបានធ្វើតែបែកភ្នំពេញខ្ញុំបានបង្រៀនពួកអករកម្មដែល។

ក៖អំ! ប៉ុន្មាននាក់ដែលរៀនជាមួយមីង។

ខ៖ច្រើនដែលជំនាន់ហ្នឹង។

ក៖ច្រើនណោះ។

ខ៖ចាំ!គ្រូអករកម្មហ្នឹងតែអស់ក្រែងឡូវជាតិក្រោយបានជាគ្រូបង្រៀនគេ។

ក៖ចុះនៅពេលដែលមីងបង្រៀនពួកគាត់ហ្នឹងមីងបង្រៀននៅណាវិញ។

ខ៖បង្រៀននៅសាលាដែលតាមផ្ទះដែលតាមភូមិដែល។

ក៖អញ្ចឹងមីងដើរទៅបង្រៀនតាមផ្ទះ។

ខ៖តាមផ្ទះដូចថាទៅបង្រៀនចាស់ៗអញ្ចឹងទៅអាយុ៥០ក្មេងៗអាយុ៣០ជាងអីអញ្ចឹងណាស់កាលជំណាន់ហ្នឹងរៀនអករកម្មអ្នកដែលអត់ចេះនិយាយរួចអ្នកដែលមកពីអាពូតដែលអត់ចេះរៀនអករកម្មអញ្ចឹងបានថាក្មួយអើយសំសត់ណាស់រូបខ្ញុំទូលលក់សព្វគ្រប់បែបយ៉ាងទាំងអស់គ្រប់រស់ជាតិអស់ហើយរស់ជាតិអស់ហើយកំសត់ណាស់។

កះអញ្ចឹងដល់ពេលអ្នកមីងឥឡូវនេះអាយុប៉ុន្មានមីងមានក្តីស្រមៃថាចង់បើមុខរបបរខ្លួនឯងអត់
។

ខះបើរបបររកខ្លួនឯងខ្ញុំមិនចង់បើមុខរបបខ្លួនឯងសព្វថ្ងៃដើម្បីរកស៊ីមានលុយបានកាក់សន្សំ
ធ្វើបុណ្យសន្សំកុសល់ទៅជាតិក្រោយកុំអោយកវេទនាដូចជាតិនេះទៀតជីវិតប៉ុណ្ណឹងមានលុយ
គេជូនមកអោយមកចូលបុណ្យខ្លាចតែគេប្រាប់អោយចូលបុណ្យតែអត់មានចូលបុណ្យគេទៀត
។

កះអញ្ចឹង។

ខះតែខ្ញុំធ្វើបុណ្យពីរដងបានខ្លួនឯងដែល។

កះធ្វើនៅវត្តណា។

ខះធ្វើនៅផ្ទះ។
ធ្វើបុណ្យនិយាយរួចទៅខ្ញុំស្រលាញ់បុណ្យណាស់ជាតិនេះតែធ្វើបើវាស្រលាញ់បុណ្យជាងអីទាំ
ងអស់ស្រឡាញ់ត្រង់ថាយើងកើតមកមិនមានម្តាយហើយយើងខំកសាងកើតជួបជុំគ្នាអំពីអកុ
សលអោយជូនផលបុណ្យហ្នឹងហើយយើងជួបត្រកូលល្អទៅខ្លាចកូនក្មួយដើរអាវាសែជក់គ្រឿ
ងញានយើងក្របកដែលអត់មាន។

កះចុះឥឡូវនេះមីងរស់នៅជាមួយតាយីមែនរឺក៏ម៉េច។

ខះខ្ញុំនៅជាមួយម្តាយមីងបង្កើតមួយមកនៅជាមួយគេដែល។

កះអញ្ចឹង។

ខះចាំ!។

កះឥឡូវនេះមីងនៅជាមួយពីណាគេ។

ខះនៅផ្ទះវីឡានោះមើលម្តាយធំជីដូនមួយអាយុ៨៧ហើយ។

កះអំ!តែនៅជាមួយខាងមីងមែន។

ខះសាច់ខាងម្តាយខ្ញុំជីដូនមួយបង្កើត។

កៈអ៎!ជីដូនមួយបង្កើតជាមួយម៉ែ។

ខៈចា៎! ធ្លាប់បៅដោះគាត់ពីក្មេងមកដែល។

កៈចុះពីមុខមកនៅជាមួយតាបន្ទាប់មក។

ខៈនៅជាមួយតាយីហើយតាយីស្លាប់អស់ទៅយីខ្ញុំស្លាប់ឆ្នាំ១៩៩៥មកនៅជាមួយម្ដាយមីងម្ដាយមួយទើបស្លាប់២០១៩ហ្នឹងទេ។

កៈបាទ!។

ខៈឥឡូវនៅម្ដាយមីងមួយទៀត៧៦ហើយប៉ុន្តែទ្រមគាត់ខ្ពស់។

កៈគាត់ឈ្មោះអីគេ។

ខៈហ៊ុន សុខ។

កៈហ៊ុន សុខអាយុ៧៦ឆ្នាំហើយ។

កៈចុះតាគាត់ឈ្មោះអីគេ។

ខៈឪពុកហ៊ុន នៅ។សុខ បូម្ដាយហ្នឹងហើយ។យីខ្ញុំហ្នឹងខ្ញុំកើតមកហៅតែម៉ែ។

កៈអញ្ចឹង។

ខៈស្មានតែម៉ែខ្ញុំមិនដឹងថាម៉ែខ្ញុំស្លាប់ចោលណាធំឡើងឃើញតែនៅជាមួយគាត់។

កៈអញ្ចឹង។

ខៈចា៎!។

កៈអញ្ចឹងខ្ញុំចង់អោយមីងប្រាប់ថាអញ្ចេកដោយសារតែមីងចង់ថាមីងអាចផ្ដែរផ្ដាំកូនចៅជំនានក្រោយរឺចៅៗទៀតណាស់មីងផ្ដែរផ្ដាំអ្វីខ្លះដើម្បីអោយពួកគាត់ខំរៀន។

ខៈផ្ដែរផ្ដាំអោយខំរៀនសូត្រអនាគត់អោយបានល្អធ្វើគំរូអោយបានសិក្សាខ្មែរល្អកុំអោយហ្នឹងហើយត្រូវស្រលាញ់ស្នេហ៍ជាតិស្នេហាទឹកដីជាតិ សាសនា
ព្រះមហាក្សត្រកុំអោយបាត់បង់ចេះរក្សាអោយបានល្អកុំអោយនេះរៀនអោយបានឆាប់អោយបានប្រាជ្ញាអោយកូនចៅជំនាន់ក្រោយអោយខំរៀនសូត្រតស៊ូកុំធ្វើក្មេងពាលាអាវាសែអត់បាន

ទេអត់ស្រលាញ់ម៉ងសព្វថ្ងៃតាំងពីដើម្បីគេចេះផឹកចេះស៊ីខ្ញុំអត់ទេរឿងហូបចុកស្វ៉ាហ្នឹងអត់ម៉ង ។ចាំ!។

កៈហើយចុះឃើញក្មេងៗជំនាន់គេដើរផឹកស៊ីអញ្ជឹងមីងជួយផ្តល់យោបលតិចទៅ។

ខៈខ្ញុំប្រដែលប្រដៅដែលតើណែនាំកូនក្មេងកុំអោយផឹកហូបច្រើនពេកព្រោះជាតិសុរ៉ាមានជាតិអាស៊ីតច្រើនពេកអីអញ្ជឹងកើតពោគកើតអីអញ្ជឹងណាស់ហ្នឹងហើយហើយវាមិនល្អទេយើងត្រូវអោយដឹងបានកូនច្រើនអោយខំចិញ្ចឹមកូមចិញ្ចឹមចៅកុំអោយស្រវាតផឹកស៊ីដើរលេងអាវ៉ាសាមិនបានទេ។ចាំ!។

កៈចុះមីងមានដែលលើកទឹកចិត្តគាត់អោយគាត់ខំរៀន។

ខៈអ៎!
ក្មេងខំក៏វារៀនដែលរៀនបានច្រើនដែលសព្វថ្ងៃនេះវាឈប់រៀនឪពុកវាស្លាប់ទៅមានបានតស៊ូទេរៀនបានថ្នាក់ទី១២ដែលអាបងនោះ។ ផាត
សុជាតិហ្នឹងរៀនបានថ្នាក់ទី១២ដែលតើប៉ុន្តែអាទី២បានត្រឹមថ្នាក់ទី៦ទេ។

កៈម៉េចអញ្ជឹង។

ខៈដូចថាវាលេងបាលច្រើនពេកអោយវាឈប់រៀនទៅពុកវាស្លាប់ទៅវានៅតូចពេក។

កៈម៉េចមីងមិនអោយគាត់រៀនតទៅទៀត។

ខៈរៀនលទ្ធិភាពយើងគ្មានអីតស៊ូទេយើងសុទ្ធតែគ្មានមនុស្សប្រុសក្នុងផ្ទះសុទ្ធតែស្រីអត់មានទីពឹងតែប់វាខំរៀនអោយអោយតស៊ូតប្រេវាមកលេងបាលពេកខ្ញុំអោយឈប់រៀនម៉ងទៅខ្ញុំមិនស្រលាញ់អារបបហ្នឹងអោយថារៀនច្បាស់ជារៀនម៉ងតែមីពៅរៀនបានថ្នាក់ទី៩ដែល។

កៈអ៎! ទី៩ឈ្មោះអីគេ។

ខៈឈ្មោះអាផាតស្រីលក្ខណ៍ថ្នាក់ទី៩។
មួយទៀតកូនក្រោយក៏រៀនបានច្រើនដែលមកអាទី៣រៀនមិនបានច្រើនទេបានថ្នាក់ទី៣សម័យនេះឈ្មោះផាត
វិសាលអត់បានរៀនច្រើនទេអន់ជាងគេមួយហ្នឹងអាបងរៀនបានថ្នាក់ទី១២ដែលហ្នឹង។

កះចុះស្រីលក្ខណ៍ហ្នឹងរៀនថ្នាក់ទី៩។

ខះទី៩។

កះហើយគិតថាអោយគាត់រៀនដល់ចប់ទេ។

ខះចប់អីឪពុកវាស្លាប់វានេះដែលហ្នឹង។

កះកាលឪពុកកូនហ្នឹងស្លាប់កូនហ្នឹងអាយុប៉ុន្មាន។

ខះអាយុប្រហែលជា៦ឆ្នាំជាង។

កះនៅតូចដែលហ្នឹងអញ្ចឹងប្រហែលថ្នាក់ទី១ដឹង។

ខះចាំ!
ថ្នាក់ទី២ហើយតូចដែលហ្នឹងរៀននៅព្រែកលោងបានពួកខ្ញុំស្រលាញ់តែអ្នករៀនអ្នកចេះយើងសរសេរថាយើងកើតមកកំព្រាម្តាយឪពុកមិនបាននៅជីដូនជីតាអោយរៀនអោយចេះយើងបានចេះអក្សរភាសាងសាក្រិចក៏ខ្ញុំមើលដាច់ដែល។

កះអ៎!។

ខះខ្ញុំមើលដាច់ដែលជំនាន់មុខជំនាន់នេះមើលភាសាសងសាក្រិចមិនដាច់ទេនិយាយរួចទៅ។

កះហ្នឹងហើយ។

ខះខ្ញុំវាស្តាយខ្លួនខ្ញុំដែលខ្ញុំមិនបានរៀនច្រើនហ្នឹងគេកាលហ្នឹងគេហៅទៅប្រលងតែមិនបានទៅ។

កះម៉េចអញ្ចឹង។

ខះខឹងដូចថាធ្លាប់ប្រលងចាញ់គេមួយលេខឈប់ទៅរៀនម៉ង។និយាយរួមទៅប្រលងចាញ់គេមួយលេខឈប់ទៅរៀនទៅមួយទៀតនឹកឃើញជីវភាពគាត់ គាត់នៅចំការរាល់ថ្ងៃ។

កះហ្នឹងហើយ។

ខះបងយើងរៀនហើយជំនាន់ហ្នឹងឃុំកោះឧញ៉ាតីប្រលងជាប់តែពីរនាក់គត់ជាប់តែបងខ្ញុំមួយជាប់អាលីមួយតែពីរនាក់គិតកោះឧញ៉ាតីកាលជំនាន់លុននុលខ្ញុំប្រាប់។

ក៖អ៎!។

ខ៖បានតែពីរនាក់ហ្នឹងបងខ្ញុំមានសញ្ញាបត្រឌីភ្លូមទាំងពីសង្គម។

ក៖អញ្ចឹងអ៊ុំគិតថាដោយសារតែអ៊ុំនៅជាមួយគេ។

ខ៖នៅជាមួយជីដូនបើទៅរៀនទាំងពីរមិនកើតយើងត្រូវការជួយការដែលជួយគាត់ចាស់គាត់មិនអោយធ្វើអីទេនិយាយរួចទៅចំការខ្ញុំមិនសូវចុះទេនិយាយខ្ញុំស្រណុកម៉ងលំបាកតែសម័យនេះទេ។

ក៖កាលហ្នឹងយីតាដែលអ្នកមីងនៅជាមួយគាត់មានកូនចៅអត់។

ខ៖កូនចៅខ្ញុំប្រាប់ម៉េចនោះ។

ក៖អញ្ចឹងកូនចៅហ្នឹងគេជួយ។

ខ៖ហ្នឹងហើយជួយយើងគាត់ចុះចំការគាត់ពិការជើងតែគាត់ចុះធ្វើចំការនៅធ្វើអីបាននៅដាំបាយដាំទឹកអីអោយយើងហូបណាស់គាត់ស្លាប់នៅឆ្នាំ២០១៩។។

ក៖គាត់ជួយច្រើនដែល។

ខ៖គាត់ជួយច្រើនណាស់ជីដូនជីតាខ្ញុំរកគ្មានទេពីណាមកនៅអាមួយខ្ញុំការអោយហ្នឹងបានសញ្ញាបត្រឌីភ្លូមសម័យហ្នឹងបានសញ្ញាបត្រឌីភ្លូមអាវា
សីថេងអោយវាទៅប្រលងវាមិនទៅប្រលង។

ក៖ម៉េចអញ្ចឹង។

ខ៖មិនដឹងម៉េចវា
វាមិនទៅប្រលងហ្នឹងហើយវាអញ្ចឹងណាស់បានថាគាត់បង្រៀនយើងអោយយើងចេះហើយខ្ញុំរពីតាយីខ្ញុំអោយវាចេះទៀតបានសញ្ញាបត្រអោយវាចេះអក្សរកុំអោយល្ងង់យើងជួយគេពេលយើងដើរទៅណាគេជួយយើងវិញ។

ក៖ហ្នឹងហើយ។

ខ៖យើងគិតប៉ុណ្ណឹងបានហើយបានរាល់ថ្ងៃខ្ញុំសរសេរខ្លួនឯងដែលដើរទៅណាគ្មានគ្រោះថ្នាក់អីគេខ្ញុំជិះឡានក៏ដោយខ្ញុំមិនដែលមានគ្រោះថ្នាក់អីទេដូចថាទេវតាជួយថៃខ្ញុំម៉ងដូចថាមនុស្សខ្ញុំ

ចិត្តល្អមាននៅក្នុងខ្លួនយើងទៅណាក៏មិនលំបាកដែលនិយាយរួចទៅបើយើងចិត្តមិនល្អទេវតាមិនថែរក្សាយើងទេហ្នឹងហើយ។

កៈអញ្ចឹងខ្ញុំចង់សួរថាខ្ញុំអាចយកការសំភាសន៍របស់អ្នកមីងថ្ងៃនេះទៅចាក់ផ្សាយនៅសកលវិទ្យាល័យនៅអាមេរិចបានទេមីង។

ខៈស្រេចលើក្មួយតើ។

កៈអរគុណច្រើន។

ខៈសកលវិទ្យាល័យមីងគ្រាន់តែសូមពរថាកូនចៅក្មួយសព្វថ្ងៃមានការលំបាកច្រើនចង់រៀនបន្ទាប់ទៀតដូចថារៀនក្រៅលុយដូចមិនគ្រប់គ្រាន់ចង់ថាអោយមានថវិការអោយវារៀមគួរអងគ្លេសអោយវារៀនអីសព្វគ្រប់ទៅណាស់តែវាខ្វះខាត។

កៈអញ្ចឹងពួកគាត់រាល់ថ្ងៃមិនបានរៀមអងគ្លេសទេ។

ខៈរៀននៅសាលាតែគេមិនយកលុយទេណាស់តែក្រៅមិនបានរៀនទេ។

កៈសាលាអីគេ។

ខៈសាលាឈ្លៀតព្រឹកថ្ងៃវារៀនមួយម៉ោងៗ។

កៈហ្នឹងខាងអង្គការមែន។

ខៈខាងអង្គការគេមិនយកលុយ។

កៈមានស្គាល់ឈ្មោះ។

ខៈខ្ញុំមិនស្គាល់ទេទាន់តែចៅខ្ញុំបានស្គាល់។ចាំ!
អញ្ចឹងបានថារាល់ថ្ងៃខ្វះថវិការអោយវារៀនគួរក្រៅបើមានថវិការមានគួរក្រៅអាហ្នឹងមិនអីទេ។ចាំ!
អូនអែងគិតពិចារណាទៅកូន៥ប្រាក់ខែ២០០$ស៊ីគ្រប់អត់វាមិនគ្រប់គ្រាន់អូនអែងគិតមើលទៅទឹកភ្លើងអង្កមួយប៉េជាង១០ម៉ឺនគិតទៅម្ហូបថ្លៃជាងអង្កទៀតតើអូនអែងគិចពិចារណាទៅគ្រប់គ្រាន់អត់។

កៈអត់គ្រប់។

ខ៖ចាំ!
មិនគ្រប់ទេអញ្ចឹងបានថាគ្រាន់តែសុំឈ្លាមពរបងប្អូនអ្នកនៅអាមេរិចអីមានសប្បុរសជនអីជួយ
គ្រួសារខ្ញុំផង។

ក៖អញ្ចឹងអរគុណច្រើនដែលមីងអោយខ្ញុំសំភាសន៍ថ្ងៃនេះ។

ខ៖ចាំ!

ក៖អរគុណច្រើន។

ខ៖ចាំ!ខ្ញុំក៏សូមអរគុណដែល។